# ការសំភាសន៍របស់អ្នកមីង ឈួន ស្រី ហៅគង់ ចាន់សុផានី

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ ឈួន ស្រី

## <u>ជីវប្រវត្តសង្ខេមរបស់អ្នកមីងឈួន ស្រី ហៅគង់ ចាន់សុផានី</u>

អ្នកមីង ឈួន ស្រី ជាអ្នកកើតនៅក្នុងស្រុកស្អាង ហើយគាត់មានបងប្អូន១២នាក់ហើយស្លាប់អស់៨ហើយ ហើយមានមួយចំនួនស្លាប់នៅក្នុងរបបប៉ុលពត!! ម្តាយអ្នកមីងជាអ្នករកស៊ីឈ្នួលគេដើម្បីចិញ្ចឹមកូនហើយឪពុកជាទាហាននៅក្នុងរបបលន់ នល់ ហើយពេលសង្គ្រាមប៉ុល ពតចូលមកឪពុករបស់គាត់បានបែកផ្លូវពីម្តាយនឹងកូន ថាលោរពួកគាត់បានរស់ខ្លាចតែទៅជាមួយគ្នាស្លាប់ទាំងអស់ ហើយកូនៗទៅជាមួយម្តាយទាំងអស់។ អ្នកមីងបានកើតទាន់ជីដូនជីតាខាងម្តាយតែខាងឪពុកគាត់បានស្លាប់គាត់ពុំបានស្គាល់ទេ គ្រាន់តែត្រឹមឮពីបងប្អូនជីដូនមួយ។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះ ពួកយើងសំភាសន៍នៅក្នុងខែមិនា ឆ្នាំ២០១៨។ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា។ អញ្ចឹងនាងខ្ញុំសូមិចាប់ផ្តើមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងមានដូចតទៅ អ្នកមីងឈ្មោះពេញឈ្មោះអីគេដែរអ្នកមីង?

ខៈ ចាំ!!ញ៉ុមដាក់ឈ្មោះឈួន ស្រី!!

កៈ ឈួន ស្រី?

ខៈ ចាំ!!

កៈ អ្នកមីងក្រៅពីឈ្មោះឈួន ស្រីអ្នកមីងមានឈ្មោះអីហៅខាងក្រៅអីទៀតអត់?

ខៈ មាន។

កៈ គេហៅអីគេវិញអ្នកមីង?

ខៈ ញ៉ុមកាលមុនឈ្មោះញ៉ុមប៉ាញ៉ុមដាក់ឈ្មោះគង់ ចាន់សុផានី។

កៈ ហីពិរោះទៀតហ្នឹងហាំ!!

ខៈ ហ្នឹងឈ្មោះដើម ឈ្មោះដើមញ៉ុមម៉ង!!

កៈ ហ្ហ៎!!អ៊ីចឹងឈ្មោះដើមឈ្មោះគង់ ចាន់សុផានីទេអ៊ីចឹង?

ខៈចាំ!!

កៈ ហេពិរោះណាស់!!

ខៈ តែអានេះគេហៅមានកូនស្រីពីរនាក់គេដាក់ងារ!!

កៈ ហ្ហ៎!!ហាកហើយមិនដាក់ឈ្មោះកាលពីមុនមក?

ខៈ ដល់យើងដាក់ឈ្មោះមុនគេអត់ស្គាល់ គេអត់ស្គាល់ទេ!!

កៈ ចាំ!!

ខៈ កាលមុនញ៉ុមធ្វើប្លង់ធ្វើអីដាក់ឈ្មោះអញ្ចឹងគេអត់ស្គាល់ឈ្មោះយើង!!

កៈ ហាំ!!តែតែឈ្មោះយើងម៉េចឈ្មោះអញ្ចឹងហើយ!!

ខៈ យើងអញ្ចេះហើយ យើងមកអញ្ចេះរហូតមកអញ្ចឹងហើយ!!

កៈ ចាំ!!

ខៈហើយអានោះឈ្មោះយើងអត់ដែលហៅហាំ!!

កៈ ហៅស្រីៗអញ្ចឹងមកក៏ជាប់ដាក់ឈ្មោះស្រីអញ្ចឹងទៅ?

ខ៖ចា៎!!

ក៖  តាមពិតតាំងពីកើតមកឈ្មោះសុផានីទេ?

ខ៖ចា៎!!

ក៖  មីងដូរឈ្មោះហ្នឹងមកប៉ុន្មានឆ្នាំហើយ?

ខ៖ ដូរប៉ុន្មានឆ្នាំហើយ ដូរយូរហើយ!!

ក៖  តាំងពីក្មេងមកឬក៏មានប្ដីហើយឬក៏មុនមានប្ដីទៀត?

ខ៖ តាំងពីពេលអត់ទាន់មានប្ដីណោះ!!

ក៖ ហ្វ៎យូរហើយអញ្ចឹងណោះ!!!!

ខ៖គេហៅគេដាក់ងារ!!

ក៖ ចា៎!!

ខ៖ ព្រោះអីប្អូនញ៉ុមមួយ ប្អូនញ៉ុមនៅកំពង់សោមឈ្មោះផានិ។

ក៖ ចា៎!!

ខ៖ ហើយឈ្មោះបុត្រ ហើយក៏គេចេះតែដាក់ងារប្រុសស្រី ប្រុសស្រី។

ក៖ ចា៎!!

ខ៖ ចា៎ហ្នឹងបានថាញ៉ុមស្អប់ណាស់អារឿងដាក់ងារជាប់!!

ក៖  ជាប់អញ្ចឹងហោ?

ខ៖ ហ្នឹងហើយៗ!!

ក៖  អ្នកមីងសព្វថ្ងៃមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ៥២។

កៈ  ៥២ឆ្នាំហើយហោ?

ខៈចាំ!!

កៈ ចាំ!!អ្នកមីងកើតឆ្នាំខ្មែរអ្នកមីងកើតសត្វអីគេវិញអ្នកមីង ចាំទេ?

ខៈ ពពៃ។

កៈ  ពពៃ មមៃ ចាំ!!អ្នកមីងចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯងទេ ថ្ងៃបារាំងឆ្នាំបារាំងអីហ្នំ??

ខៈ កត់ចូលនៅក្នុងហ្នឹង។

កៈ  ចាំ ឥឡូវមើលនៅក្នុងសំបុត្រកំនើតរបស់អ្នកមីងតែម្តងទៅ!! អញ្ចឹងអ្នកមីងឈ្មោះឈួន ស្រី កើតថ្ងៃពុធ ទី៣ ខែ មេសា ឆ្នាំ១៩៦៦។នៅភូមិរកាខ្ពស់ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាលប្រទេសកម្ពុជា។អ្នកមីង សំរាប់អ្នកមីងកើតតាំងពីដើមមករាជមកនៅហ្នឹង!!

ខៈ នៅហ្នឹង!

កៈ  លើដីទឹកដីហ្នឹងម៉ងមីងហោ?

ខៈ ចាំ!!

កៈ  អត់ទៅខាងណោះ អត់នៅខាងជាប់ទន្លេវិញ?

ខៈ កាលពេលមុនញុំមនៅខាងណោះហើយបានមកនៅខាងណេះវិញ!!

កៈ ហើយម៉េចបានប្តូរទីលំនៅមកនៅនេះវិញ?

ខៈ ប្អូន !! លុយទៅលក់ដោះដូរ!!

កៈ ហ្នំ!!អញ្ចឹងដោះដូរអីអ៊ីចឹងទៅមីងណោះ?

ខៈចាំ លក់ដោះដូរមកទិញនៅនេះវិញ។

កៈ ចាំ!!

ខៈមកទីញនៅនេះវិញ ដីរបស់បងជីដូនមួយដែរហ្នឹងទិញនៅហ្នឹង!!

កៈ  ចាំអ្នកមីងមានបាក់អីអត់ ទឹកទន្លេអីអញ្ចឹងហាំមានបាក់អីទេ?បាក់ដែរអូនហោ?

(កូន)ៈបាក់វែងឡើងមកដល់នេះហ្ន៎!!

ខៈ ពីមុនវាបាក់ឥឡូវវាអត់អីវិញ។

កៈ  ហ្ន៎!!

ខៈ ពេលមុនបាក់តើ!!

កៈ  ដល់ពេលខែទឹកឡើងបាក់ហ្នឹងហី?

ខៈហ្នឹង!!

កៈ  និយាយទៅបាក់ទន្លេហ្នឹងដោយសារគេបូមខ្សាច់ឬក៏ម៉េចវិញអ្នកមីង?

(កូន)ៈ បូម!!

ខៈ បូម!!

(មិត្តភក្តិ)ៈ គេបូមខ្សាច់បាក់!!

ខៈ ហើយយើងទាល់តែនិយាយម៉េចក៏អត់ឈ្នះគេដែរ!!

(មិត្តភក្តិ)ៈ អត់ឈ្នះគេទេ!!យើងអ្នកតូចអាតាចអត់ឈ្នះគេ!!

ខៈ នេះពួកអ្នកបូមខ្សាច់ហ្នឹង ដូចថាប្រជាជនអ្នកឡើងទៅប្ដឹងទៅអីអញ្ចឹងអត់ឈ្នះទេ!!

(មិត្តភក្តិ)ៈអត់ឈ្នះទេ!!

កៈ  មីងប៉ះពាល់ខ្លាំងណាស់មួយហ្នឹងហាំ ដោយសារអញ្ចឹងវាមិនបាក់ច្រាំង!!

ខៈ ចាំហើយអញ្ចឹងមកមកខាងញុំមណោះហាំ
កាលគេមកកាលគេចុះមកមើលដីហ្នឹងគេថាហ្នឹងគេអត់បូមទេ
ឡូតិ៍ត្រឹមហ្នឹងអត់បូមទេតែពីមុនដំបូងមកវាបូមរហូតហាំ!!!វាថាអត់បូមទេឡូតិ៍
មានឈ្មោះត្រឹមតែផ្ទះបងនីផ្ទះខ្ពស់កន្លែងតូបនោះមិញហ្នឹងហាំ!!ផ្ទះអាដើមអំពិលពីមុនហ្នឹង

ហើយថាត្រឹមឈ្មោះត្រឹមហ្នឹងទៅបូម!!ហើយត្រឹមនេះមកវាអត់បូមទេ
ហើយវាមកបូមហ្នឹងរាល់តែដងហ្នឹង!!

ក៖ ហ៊ឺៗ!!

ខ៖វាទឹមបូមហើយឥឡូវវាទៅខិតទៅណាបាត់ទៀតហើយ!!

ក៖  មីងនៅកន្លែងម្តុំហ្នឹងសុទ្ធតែខ្សាច់ម៉ងហើយមីងហេ?

ខ៖ ខ្សាច់ វាកៀងអីវា!

ក៖  ញ៉ុមឆ្ងល់ទន្លេវាសំបូរតែខ្សាច់អញ្ចឹងមីងណោះ?

ខ៖ តែកោះខ្សាច់ជន្លាគេអត់អោយបូមផងហ្នឹង!!

(កូន)៖ តំបន់គេអភិវឌ្ឍន៍។

ខ៖គេអត់អោយបូមទេ!!

ក៖ ហ៊ឺដោយសារអាការបូមខ្សាច់បូមអីហ្នឹង វាប្រឈមមុខនឹងការបាក់ច្រាំងណាស់មីងហា
ហើយអញ្ចឹងវាជះឥទ្ធិពលមកលើប្រជាជនណោះ!!

ខ៖ហ្នឹងហ្នឹង!

ក៖ បាក់ច្រាំងបាក់អញ្ចឹងមកផ្ទះមិនបាក់ចូលក្នុងដីទន្លេហ្នឹង!!

ខ៖ហ្នឹង!!ហើយញ៉ុមថាបើឥឡូវសុខចិត្តទេដូរ ដូរផ្ទះគ្នា ញ៉ុមទៅនៅភ្នំពេញ!!

(មិត្តភក្តិ)៖ និយាយជាមួយអ្នកណាគេ?

ខ៖ ពួកអ្នកមកមើលហាំ!! ហើយញ៉ុមស្មគ្រ័ចិត្តដូរទៅនៅភ្នំពេញ
ហើយផ្ទះម៉េចក៏ដោយញ៉ុមនៅភ្នំពេញ!!

ក៖ ហ៊ឺ!!

ខ៖ដូរគ្នា វាអត់ព្រមដែរតើ!!

កៈ ចាំបានអីនឹងព្រមឆ្លាតសឹងងាប់ហើយពួកអាអស់ហ្នឹង
ថានិយាយទៅវាធ្វើបាបតែអ្នកណាគេអ្នកដែលអត់មាន!!

ខៈហ្នឹង!!

(មិត្តភក្តិ)ៈ អ្នកទន់ខ្សោយ!!

ខៈ អ្នកទន់ខ្សោយ!!

កៈ ហ្នឹងហើយ!!

ខៈ យើងវាអត់អីចឹងណាស់!!

កៈ  ហ្នឹង តែគេមានគេខ្លាំងហើយអ្នកមីងណោះ?

ខៈ ហ្នឹងហើយ!!

កៈ  ទឹកមាត់គេប្រៃហើយ តែយើងអត់ អត់តាមហ្នឹងហើយ!!

ខៈយើងអត់!!

កៈ  ចាំ អ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរមីង?

ខៈ ស្រី២អទាំងញុំម។

កៈ  អញ្ចឹងទាំងអស់៣នាក់មីងហោ?

ខៈ ទាំងអស់៤!!

កៈ  ៤ហោ!!

ខៈ ប្រុសពីរស្រីពីរមួយនៅកំពង់សោម មួយនៅព្រៃកស្នាយ។

កៈ  ចាំអញ្ចឹងពួកគាត់ទាំងអស់សុទ្ធតែកើតនៅកោះគរដែរអត់អ្នកមីង?

ខៈ កើតនៅកោះគរទាំងអស់ហ្នឹង !!

ក៖  ចាំ!!

ខ៖ មានកើតនៅភ្នំពេញ!!

ក៖  ចាំអញ្ចឹង!!

(មិត្តភក្តិ)៖ តែបងសីនោះស្លាប់។

ខ៖ អើរ!!ក៏ប៉ុន្តែ៩នាក់ ភស្សពីរ បងភស្សហើយអញ ហើយប្រុសពីរឪហើយនី។

ក៖ អញ្ចឹងមីងទាំងរស់ទាំងស្លាប់ទាំងអស់ប៉ុន្មាននាក់សរុបទាំងអស់ម៉ង?

ខ៖ ហ្នំកូនច្រើន!!

ក៖ មើលមីងបងប្អូនប៉ុន្មាននាក់និយាយទាំងរស់ទាំងស្លាប់មើល?

ខ៖ ចូល១២នាក់ហ្នំ!!

ក៖  តែនៅរស់តែ៤ទេអ្នកមីងណោះ?

ខ៖ នៅរស់តែ៤ទេ។

ក៖  ហ៊ឺ!! ៨នាក់ទៀតគាត់ស្លាប់មូលហេតុអីគេវិញ?

ខ៖ មួយកាលពីអាពត ហើយមួយបងប្រុសនោះគាត់ទៅជីកប្រឡាយ អាពតហ្នឹងគេជះដីត្រូវត្រូវចំផ្លោកហ្នឹងនេះត្រូវ!!

ក៖ ហ៊ឺស!!

ខ៖ ជះដីត្រូវត្រង់ហ្នឹងហើយឡើងសន្លប់។

ក៖ ហ៊ឺទៅអញ្ចឹង!! ហើយចុះប៉ុន្មាននាក់ទៀតម៉េចទៀតទៅ មុនអាពតឬក៏ស្លាប់នៅក្នុងហ្នឹង?

(មិត្តភក្តិ)៖ បងស្រីមួយណាស្លាប់?

ខ៖ បងចាន់នីអញហ្នំ កាលពេលអាពតគេជះដីត្រូវ បងចាន់នី បន្ទាប់មកបងថន នេះមក វាមកវាឈឺ វាឈឺស្លាប់ទៅបងៗញ៉ុមហ្នឹងហាំ!!

(មិត្តភក្តិ)៖ ពេលស្លាប់ហ្នឹងបងស្រីឯងឃើញទាន់ ឃើញមុខដែរហោ?

ខ៖ អញនៅនេះប៉ុនមុីអីដែរហើយយតើ ស្គាល់តើមិនមែនថាអត់ស្គាល់ណា!!

ក៖ ហ្ហ៎!!

ខ៖ហើយបងញ៉ុមមួយពីអាពត។

ក៖ ចា៎!!

ខ៖ តែគាត់គ្រាន់តែថាអញ្ចេកក្មេងៗវាដុតចំបើងអីទៅដុតត្រូវ
គាត់ថាអូនឯងកុំដុតតែដុតឆេះត្រូវហើយ គេចាប់ពួយកទៅហើយ
គ្រាន់តែថាតែប៉ុណ្ណឹងចាប់គាត់យកដាក់រទេះទៅទៅ!!

ក៖ ហ៊ឺៗ!!

ខ៖ ហ្នឹងហើយគ្រាន់តែថាអញ្ចឹងសោះហ្នឹង!!

(មិត្តភក្តិ)៖ គ្រាន់តែថាអញ្ចឹងហ្នឹងសោះហ្នឹង!!

ក៖ ដូចអត់មានមូលហេតុអីសោះហ្នឹងហា៎!!

ខ៖ ហ្នឹងអត់មានទៅត្រូវយកគាត់ទៅសម្លាប់អីផង។

(មិត្តភក្តិ)៖ ប្រាប់ល្អសោះ!!

ខ៖ ហ្នឹងប្រាប់ល្អសោះហ្នឹង។

ក៖  ហើយកូន កូនដែលពួកអាប្រាប់ហ្នឹងកូនពួកអាពតហ្នឹងមីងហោ?

ខ៖ កូនពួកយើងអញ្ចឹង!!

ក៖ ហាហើយអ៊ីចឹងអ្នកណាគេជាអ្នកព្ទទៅ?

ខ៖ ហើយដូចក្មេងៗវានៅហ្នឹងទៅ ហើយដូចថាអ្នកគេដើរមកទៅយើងនិយាយអ៊ីចឹងទៅ !!

ក៖ ហ៊ឺ!!

ខ៖ ហើយគេយកយើងយកទៅវ៉ៃចោលទៅ។

ក៖  គ្រាន់តែពាក្យប៉ុន្មានម៉ាត់សោះហ្នឹងធ្វើអោយបាបគ្នាដល់ករ។

ខ៖ ហ្នឹងគេយកទៅហើយញ៉ុមនៅបងប្រុសញ៉ុមមួយទៀត!!

ក៖  ចាំ!!អញ្ចឹងអ្នកមីងឥឡូវ១២នាក់ឈ្មោះទាំងអស់
ឈ្មោះទាំងអស់ដែលអ្នកមីងចាំអញ្ចឹងហា?បើបើសិនជាមួយណាអត់ចាំក៏អត់អីដែរ
តែរៀបរាប់ទាំងស្លាប់ទាំងរស់ដែលអ្នកមីងបានស្គាល់អញ្ចឹងហ្ន៎!!

ខ៖ បងញ៉ុម បងញ៉ុមបងគេបង្អស់ឈ្មោះបងចាន់លី បងចាន់លីហើយបងថន
បងថនហើយបងធី បងធីហើយមក កូនភ្លោះគាត់ កូនភ្លោះគាត់សាលី សាឡាត!!

ក៖ ចាំ!!

ខ៖ កូនភ្លោះគាត់២នាក់ទៀតហាំ!!

ក៖  ចាំអញ្ចឹងបាន៥នាក់ហើយ អញ្ចឹងនៅសល់៧នាក់ទៀត អ្នកណាគេវិញអ្នកមីង?

ខ៖ ឈ្មោះអីគេទៀតទេ!!ហើយកូនគាត់អ្នកណាគេខ្លះទៀតទេ
ដូចថាស្លាប់ទៅញ៉ុមអត់ទាន់អញ្ចឹងហាំ!!

ក៖ ចាំ!!

ខ៖ញ៉ុមទាន់បងប្អូនប៉ុន្មាននាក់ហ្នឹង!!

ក៖ ចាំអញ្ចឹងស្គាល់តែ៥នាក់ហ្នឹងទេមីងហេ?

ខ៖ ហ្នឹងហើយ!!

ក៖  ចុះអ្នកដែលនៅរស់ឈ្មោះអីគេវិញ?

ខ៖ ប្អូនញ៉ុមមួយនៅភ្នំពេញ ឈ្មោះសម្ភស្ស !!

ក៖ ចាំដល់ពេលបង?

ខ៖ បងញ៉ុមនៅព្រៃកស្វាយឈ្មោះបងឌី។

ក៖ ចា!!

ខ៖ ហើយប្អូនញ៉ុមនៅកំពង់សោមឈ្មោះផានិ។

ក៖  ចាំ គាត់នៅផ្ទុំណាវិញអ្នកមីងនៅកំពង់សោមអ្នកមីង?ទីក្រុងម៉ងឬក៏ទៅណា!!

(កូន)៖ ម្តុំជិតឆ្នេរ !!

ក៖  ហ្ហ៎នៅជិតឆ្នេរ!!

(កូន)៖ នៅក្បែរផ្សារហ្ហ៎!!

ក៖  ហ្ហ៎!! ផ្សារលើហ្នឹងហេ?

(កូន)៖ ផ្សារកន្លែងទិញឥវ៉ាន់ នៅជិតឈូងសមុទ្រហ្ហ៎!!!

ក៖ ចាំ!!

(កូន)៖ ដូចថានេះផ្សារអញ្ចឹងផ្ទះគាត់មានផ្លូវកាត់នេះនៅកន្លែងនេះ!!

ក៖ ហ្ហ៎!!អញ្ចឹងមីងទៅលេងសមុទ្រអីស្រួលណាស់មីង មានផ្ទះនៅស្រាប់!!

ខ៖ មិនដែលទៅទេ។

ក៖
ចាំអញ្ចឹងអ្នកមីងសំរាប់ពួកគាត់ទាំងអស់ដាក់ត្រកូលឈូនឬក៏ត្រកូលអីគេ?ដាក់ត្រកូលហាំ??

ខ៖ ខ្លះគេដាក់ខុសញ៉ុម ខ្លះគេដាក់ម៉ម។

ក៖  អ្នកខ្លះដាក់ឈូន អ្នកខ្លះដាក់ម៉ម?

ខ៖ចាំ!!

ក៖  ត្រកូលខាងតា?

ខ៖ត្រកូលខាងតាខាងអីអញ្ចឹងទៅណាស់!!

ក៖ ចា!!

ខ៖ ដាក់ខុសៗគ្នា!!

ក៖
ចាំហ្នឹងហើយ!!មីងមើលមីងនិយាយពីអនុស្សាវរីយ៍អ្នកមីងជាមួយបងប្អូនអ្នកមីងអាចរៀបរាប់ពីជីវិតអ្នកមីងជាមួយបងប្អូនថាពីទូចៗមកធ្លាប់លេងអីគេខ្លះជាមួយគ្នាធ្វើការអីគេខ្លះជាមួយគ្នាអញ្ចឹងហាំ ស្រម៉ៃនឹកពីអតីតកាលតិចមើល?

ខ៖ គ្រាន់ថាអតីតកាលញ៉ុម ញ៉ូមឈឺច្រើនជាគេពីក្មេង!!

ក៖ ចាំ!!

ខ៖ម៉ាក់ញ៉ុមឧស្សាហ៍យកញ៉ុមទៅពេទ្យ!!ហើយបងញ៉ុម ញ៉ុមនៅពីទូចក្មេងទូចហ្នំ
បងញ៉ុមកាត់សក់ សក់ ញ៉ុមទឹមតែអង្គុយឯក់ដើកឯក់ដើកហ្នឹងជុងកន្ត្រៃ
ក្បាលនេះជុងកន្ត្រៃហិ!!

ក៖ អូយ!!

ខ៖ ជុងកន្ត្រៃហាំ អោនទៅហើយដល់ពេលនេះទៅបងញ៉ូមបងញ៉ុម
បងប្រុសញ៉ុមដែលថាគេជះដីត្រូវហ្នឹងមូលដៃគាត់បាក់ហា!!

ក៖ ហ៊ីចំមូលសាហាវម្ល៉េះដល់បាក់ដៃ!

ខ៖ មូលទៅដៃគាត់អញ្ចេកដៃបងញ៉ុម បងនៅអាពតហ្នឹង!!

ក៖ ចាំ!!

ខ៖ ថាបងញ៉ុមស្លាប់ពីអាពតហ្នឹងធ្វើបាប គាត់ស្រលាញ់តែប្អូនស្រីមានតែមួយ
បងប្អូនស្រីគេមានតែប្អូនស្រីមួយ។

ក៖  ចាំ!! អ៊ីចឹងពេលហ្នឹងមីងមានតែស្រីតែមួយទេអ៊ីចឹងហោ?

ខ៖ ស្រី២ !!តែក្រោយមកម៉ាក់ញ៉ុមបានស្រីមួយទៀត!!

ក៖ ចា៎ អ៊ីចឹងពេលមុនមកបងសុទ្ធតែប្រុសៗទាំងអស់?

ខ៖ សុទ្ធតែប្រុស។

ក៖  ចា៎អ៊ីចឹងបងប្អូនមីងស្រីៗតែ២នាក់ហើយហើយក្រៅពីហ្នឹង១០នាក់សុទ្ធតែប្រុសទាំងអស់?

ខ៖ ដល់តែក្រោយទៀតបានស្រីពេលនៅអាពតអ៊ីចឹងហា៎!!

ក៖ ចា៎!!

ខ៖ បានមួយទៀតហ្នឹងមុនអាពតហ្នឹងបានកូនស្រីមួយទៀត។

ក៖ ចា៎!

ខ៖ថាញ៉ុមបង!!

ក៖  មីងធ្លាប់លេងអីគេខ្លះជាមួយពួកគាត់នៅផ្ទះនៅអីអ៊ីចឹងហា៎ លេងអីគេខ្លះទៅមីង?

ខ៖ មិនសូវលេងអីគេទេញ៉ុម!!

ក៖  ដូចថាលេងបាញ់កៅស៊ូ ឆ្កឹះកៅស៊ូអីអ៊ីចឹងទៅណាស់!!

ខ៖ កាលញ៉ុមនៅពីក្មេងលេងតែលោតអន្ទាក់។

ក៖ ហ្ន៎ ជាមួយពួកគាត់អ៊ីចឹងទៅមីងណោះ?

ខ៖ លេងលោតអន្ទាក់លេងលោតអីអញ្ចឹងទៅ!!

ក៖  ចា៎ លេងអីជាមួយគាត់អ៊ីចឹងទៅ?

ខ៖ចា៎!!

ក៖  មីង បងប្អូនទាំងអស់ ទាំង១២នាក់ហ្នឹងមីងស្រលាញ់មួយណាជាងគេឬក៏ស្មើគ្នា?

ខ៖ ស្មើគ្នា បងប្អូនស្អប់អី ស្រលាញ់ទាំងអស់។

កៈ  ចាំមីង មីងទាំងអស់ហ្នឹង
មីងជិតស្និតជាមួយអ្នកណាគេវិញ?ស្រីឬក៏ប្រុសដែរជិតស្និតជាងគេ?

ខៈញ៉ុមដូចថាបងប្អូនប្រុសដូចថាមិនសូវជិតស្និតដូចបងប្អូនស្រីទេ!!

កៈ ចាំ!!

ខៈ ស្រីដូចថាជិតស្និតជាង។

កៈ  ចាំ ឥឡូវមានទំនាក់ទំនងល្អជាមួយគាត់តើមីងហី?

ខៈ ចាំ!! បងប្អូនញ៉ុមមានអី បងប្អូនប្រុសញ៉ុមក៏ញ៉ុមស្រលាញ់ដែរ
ព្រោះអីញ៉ុមមានតែបងប្អូនញ៉ុប៉ុណ្ណឹងហ្នឹងមីអូនណាស់!!

កៈ ចាំ!!

ខៈ បងប្អូនយើងមានតែ៩នាក់ ។

កៈ ពួកគាត់ពេលមីងមានកម្មវិធីអី ឬក៏មានទុក្ខលំបាកអីពួកគាត់អីវ៉ាន់ជួយមីងច្រើនដែរមីងហី?

ខៈ គាត់ជួយអីបន្តិចបន្តួច គាត់អត់ដែរហ្នឹង!!

កៈ ចាំ!!

ខៈ ប្តីញ៉ុមស្លាប់ហើយគាត់ជួយតិចតួចអីអញ្ចឹង!!ពួកគាត់អត់ដែរហ្នឹង!!អត់ដែរ។

កៈ  ចាំ!! តែក៏មិនសូវអីណាស់ណាដែរមីងណោះ?

ខៈ តែបងញ៉ុមនៅព្រែកស្នាយរៀងយ៉ាប់ដែរហ្នឹង!!

កៈ  គាត់ម៉េចវិញមីងបានយ៉ាប់?

ខៈ គាត់អត់!!

(កូន)ៈគាត់ចាញ់បោកគេ។

ខៈ តែញ៉ុមក៏មិនមានអីណាប៉ុន្មានដែរ!!

កៈ ចា៎!!

ខៈ ញ៉ុមអត់ដែរហ្នឹង ដូចថាលុយតិចតួចអីចឹងញ៉ុមអត់ហ៊ានចាយទេអត់អីអីចឹងទៅណាស់ញ៉ុមទុកផ្សំធ្វើផ្ទះធ្វើអី។

កៈ ចា៎!!

ខៈ យើងអោយបានផ្ទះនៅទៅ យើងកុំអោយពេលភ្លៀងដើរច្រកផ្ទះគេ។

កៈ ហ្នឹងហើយ!!

ខៈ វាពិបាកវេទនា!!

កៈ និយាយទៅមីងអោយតែអត់មានរបស់អីខ្លួនឯងវាពិបាកហ្នឹងហា៎មីងហា៎!!

ខៈ ចា៎!!

កៈ វាពឹងពាក់លើគេវាមិនស្រួលប៉ុន្មានទេ!!

ខៈចា៎!!

កៈ ចា៎!!ហ្នឹងហើយ ចា៎ម៉េចអ្នកមីង?

ខៈ នៅផ្ទះហ្នឹងថាម៉េចថាទៅ ដូចថាញ៉ុមសព្វថ្ងៃហ្នឹងញ៉ុមអត់មានអីទេញ៉ុមក្រដែរ។

កៈ ចា៎ គ្រាន់តែមួយរស់ មួយរស់អីចឹងទៅមីងណោះ?

ខៈចា៎!!គ្រាន់តែមួយរស់អីចឹង គ្រាន់តែដើរកាត់ផ្ទីកាត់អីអោយគេអញ្ចឹង។

កៈ មីងស៊ីឈ្នួលកាត់ផ្ទីអោយគេតើហី?

ខៈ ចា៎!!

កៈ មិនមែនដាំខ្លួនឯងទេហោ?

ខៈ ញ៉ុមអត់មានដីទេ!!

កៈ ហ្ហ៎!!

ខៈ ញ៉ុមអត់មានដីទេ!!

កៈ  កាត់ផ្ទីហ្នឹងគេគិតអោយម៉េចដែរមីង?

ខៈ កាត់មួយគីឡូ៣០០ !!

កៈ  ហ្ហ៎បានច្រើនដែរតើអ៊ីចឹង!! អ៊ីចឹងបើកាត់រាប់រយគីឡូហ្នឹងក៏ឃើញអញ្ចឹងដែរ!!

ខៈ គេមានកាត់គេហៅទៅ អត់អត់ទៅ។

កៈ ចាំ!!!

(មិត្តភក្តិ)ៈ មួយគីឡូៗតិចតែមួយហ្នឹង!!

កៈ  ហ្នឹងហើយ វានេះវាល្មមៗដែរហ្នឹងហាំ!!

ខៈ ហ្នឹងហើយ តែច្រើនដែរហ្នឹង ២០គីឡូហ្នឹង យើងកាត់ច្រើនដែរហ្នឹងមីង
យើងកាត់ឡើងមួយស្បោងឡើងណៃន ទំរាំតែបាន២០គីឡូ!!

កៈ ចាំ!!៦០០០!!

ខៈហ្នឹង!!

កៈ  ពិបាកណាស់ទំរាំបាន២០គីឡូ។អ្នកមីងម្ដាយអ្នកមីងគាត់ឈ្មោះអីគេវិញ?

ខៈចាំ?

កៈ  ម្ដាយហាំ?

ខៈ សាម ឡេង។

កៈ  សាម ឡេង!!

ខៈចាំ!!

ក៖  ចាំអញ្ចឹងនៅក្នុងសំបុត្រកំណើតរបស់អ្នកមីង ម្ដាយអ្នកមីងគាត់ឈ្មោះសាម ឡេង គាត់កើតនៅក្នុងឆ្នាំ១៩៤០ នៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា។ មីងចាំឆ្នាំខ្មែររបស់ម្ដាយអ្នកមីងទេ?គាត់កើតឆ្នាំអី?

ខ៖ អត់ចាំទេ!!

(មិត្តភក្តិ)៖ សត្វអី ឆ្នាំខ្មែរយើង?

ខ៖ គាត់ដូចឆ្នាំជូតហេឆ្នាំខ្មែរយើង!!

(មិត្តភក្តិ)៖ ជូត ដូចជ្រូកហេ!!

ក៖  ជូត កណ្ដុរ!!ហ្នឹងហើយ គាត់កើតឆ្នាំកណ្ដុរ!!
ហ្នឹងហើយអ្នកមីងគាត់ស្លាប់ឬក៏នៅរស់?ម្ដាយរបស់អ្នកមីង?

ខ៖ គាត់ស្លាប់ហើយ។

ក៖  គាត់ស្លាប់ពីជំនាន់ណាវិញ?

ខ៖ យើងបែកអាពតហើយយូរដែរ គាត់កើតទាចទឹកហាំ!!

ក៖  គាត់ម៉េចកើតមួយហ្នឹង
ទាចទឹកភាគច្រើនកើតភាគច្រើនអ្នកដែលផឹកស្រាបានភាគច្រើនកើត!

ខ៖ គាត់ហូបហាំ!!

(កូន)៖គាត់ហូបស្រា!!

ក៖  ហ្ហ៎ូ!!

ខ៖ គាត់ផឹកព្រលឹមឡើង៥០០ ៥០០ អ៊ីចឹងទៅណាស់!!

ក៖ ហ្ហ៎ូ!!

ខ៖ ដល់នេះទៅវាកើត!!មើល មើលទៅណាទៅតែពីរនាក់គាត់
ទៅពេទ្យណាទៅពេទ្យស្នឹងមានជ័យទៅតែពីរនាក់គាត់ មើលទៅដូចថាកំសត់ណាស់។

កៈ  អ៊ីចឹងមីងស្និតស្នាលជាមួយម្តាយខ្លាំងហោ?

ខៈ ចាំ!!

កៈ  ចាំ!!

ខៈ ប្អូនញ៉ុមមួយពៅអត់ស្ងួរទេ!!គ្រាន់តែថាប្អូននៅកំពង់សោមហ្នឹង
គេមានលុយអីតិចតួចអ៊ីចឹងគេផ្ញើមកអោយអ៊ីចឹងទៅណាស់!!

កៈ ចាំ!!

ខៈ យើងទិញអីៗអោយគាត់ហូបអ៊ីចឹងនៅនៅពេទ្យអ៊ីចឹងទៅ!!ស្រាកគ្នាតិចៗមើលអញ្ចឹងទៅ!!

កៈ  ចាំហ្នឹងហើយ អ៊ីចឹងអ្នកមីងសំរាប់ម្តាយរបស់អ្នកមីងដើម្បីរកស៊ីចិញ្ចឹមគ្រួសារនិងកូន
គាត់រកស៊ីអីគេដែរមីង?

ខៈ គាត់មុនគាត់ធ្វើស្រូវធ្វើអីអញ្ចឹងដែរហ្នឹងហាំ!! ធ្វើស្រូវ ដើរស៊ីឈ្នួលស៊ីគេអញ្ចឹងទៅ
ដល់នេះគាត់ចាស់ទៅ គាត់ដើរហើយដើរហើយញ៉ុមរកចិញ្ចឹមវិញ។

កៈ ចាំ!!

ខៈ ញ៉ុមអោយគាត់នៅផ្ទះវិញញ៉ុមដើរស៊ីឈ្នួលគេវិញ!!

កៈ ចាំ!!

ខៈ ញ៉ុមដើរធ្វើការអោយគេតាំងពីអាយុ១៥ហ្នំ!!ញ៉ុមចិញ្ចឹងប្អូននៅកំពង់សោមអី
ព្រោះអីវាអត់យើងដើរអ៊ីចឹងទៅបានលុយមកទិញសៀងចៀនពងទាអីដាក់អោយប្អូនទៅរៀន
។

កៈ ហ៊ឺៗ!!

ខៈ ញ៉ុមដើរស៊ីឈ្នួលគេ!!

កៈ  ហ្នឹងហើយ!!

ខៈ ចាំហ្នឹងហើយ ហើយញ៉ុមនិយាយទៅញ៉ុមអត់ចេះអក្សរទេ!!

កៈ ចាំ!!

ខៈ ព្រោះញ៉ុមម្តាយញ៉ុមគាត់ឈឺដល់អញ្ចឹងញ៉ុមថាឈប់រៀនម៉ងទៅ ចាំញ៉ុមនៅថែម្តាយ នៅថែម្តាយ!!

កៈ ចាំ!!

ខៈព្រោះអីអត់មានអ្នកណាគេមើល!!

កៈ ចាំ!!

ខៈ
ប្អូនញ៉ុមនៅភ្នំពេញហើយមានញ៉ុមមួយនៅស្និតស្នាលតែគាត់មួយហ្នំ!!ដល់អញ្ចឹងយើងនៅមើលគាត់ មើលថែគាត់ ដល់នេះទៅអោយប្អូននេះទៅអញ្ចឹងទៅ!! ដល់គាត់ទៅដេក ដេកពេទ្យ២ ៣សារ អត់ជា!!

(មិត្តភក្តិ)ៈ ហេអាទាចទឹកហ្នឹងមើលអត់ជាម៉ង!!

ខៈ ចាំ!!ញ៉ុមទៅរហូតទៅស្រែព្រៃគាត់ វិហារកំបោរណោះ!!

កៈ ចាំ!!

ខៈ ញ៉ុមទៅប៉ុន្មានខែហ្នំ ដល់ហើយទៅគេអត់អោយញ៉ុមមក
គេថាអត់អោយញ៉ុមមកជាមួយគាត់ថាលេខញ៉ុមហើយគាត់ហ្នឹងឆុង!!

កៈ ហ៊ឺ!!

ខៈ ដល់ថាអាចារ្យថាឆុងអីអោយគ្នាមកហើយញ៉ុមយំហាំមីងហាំ!!

កៈ  ឆុងអី ឆុងអីមកពីគាត់ហូបស្រាហ្នឹងឆុងមកឆុងមកបន្ទោសគេកូននេះវិញ!!

ខៈ ហើយដល់នេះអត់អោយគេ គេថាអត់អោយមកទេ នៅនោះទៅ ហើយដល់មីងញ៉ុម
នេះគាត់នេះផ្ទះគាត់លក់ចាប់ហ្វៀយនេះ គាត់ទៅហាំ
គាត់អត់ដឹតងថាបងញ៉ុមយកមកបងញ៉ុមបងសីនេះ បងសីញ៉ុមស្លាប់នេះដែរ!!

(កូន)៖ ដូលម៉ូតូ!!

ខ៖ ដូលម៉ូតូ បាក់ករ បងញ៉ុមជីដូនមួយ។

ក៖  អ្នកមីងចាំអីគេខ្លះពីម្តាយដែរ គាត់ចរិកទន់ភ្លន់ឬកាចស្លូតម៉េចអ៊ីចឹងណាស់ ម្តាយរបស់អ្នកមីង?

ខ៖ មិនអីទេគាត់ស្លូតដែរ។

ក៖ ចាំ!!

ខ៖ដូចថាគាត់អត់កាចអត់អីដែរហាំ!!

ក៖  ចាំអញ្ចឹងដូចថាអ្នកមីងចាំអីគេ អនុស្សាវរីយ៍ដែលអ្នកមីងបំភ្លេចមិនបានជាមួយនឹងគាត់ហាំពេលណាវិញមីង?

ខ៖ គ្រាន់ថានេះយូរឆ្នាំមក គ្រាន់តែថាញ៉ុមនេះពីទូចមកញ៉ុមឈឺអ៊ីចឹង គាត់មើលញ៉ុមហើយដល់គាត់ឈឺវិញទៅយើងថែម្តាយវិញទៅមីអូនណាស់!!

ក៖ ចាំ!!

ខ៖ ហ្នឹងយើងចេះថែ គ្រាន់តែថាអត់ពិបាកអីយើងចេះថែ ធ្វើការធ្វើអីអញ្ចឹងយកមកចិញ្ចឹមម្តាយទៅណាស់ ។

ក៖ ចាំ!!

ខ៖ អត់ហូបអត់អីអញ្ចឹង អាហ្នឹងមិនដឹងធ្វើម៉េចបើយើងអត់ទៅរកបានអីហូប។

ក៖  ហ្នឹងហើយជីវិតគឺតែអ៊ិចឹងអ្នកមីងណោះ?

ខ៖ ដើររកចិញ្ចឹមគាត់។

ក៖  ស្រលាញ់គាត់ខ្លាំងណាស់អ្នកមីងណោះ?

ខ៖ហ្នឹង!!

កះ  ដោយសារម្ដាយជាអ្នកផ្ដល់កំណើតអោយ ថៃទាំ!!

ខះ ផ្ដល់កំនើត គ្រាន់តែថាយើងថៃគាត់ហ្នឹងក៏វាមិនមែនសងគុណគាត់អស់ដែរមើអូន។

កះ ចាំ!!ហ្នឹងហើយ!!

ខះ ១០០បានតែមួយទេ ព្រោះយើងគាត់ដូចថា
ដូចលោកទេសថាគាត់បង្កើតយើងមកអាហ្នឹងឆ្លងសមុទ្រហាំ !! អាហ្នឹងឆ្លងរួចមិនរួច!!

កះ ចាំ!!

ខះ ឆ្លងមិនរួចត្រឹមហ្នឹងហើយ។

កះ ហ្នឹងហើយ តែដោយសារអញ្ចេក ជីវិតរបស់មនុស្សគឺត្រូវតែអញ្ចឹងមកអញ្ចឹងមីងណោះ!!

ខះ ហ្នឹងហើយ!!

កះ  ដោយសារពីមួយជំនាន់ទៅមួយជំនាន់អ្នកមីង
ដូចថាគាត់បង្កើតអ្នកមីងមកមើលថៃទាំអ្នកមីងមើលថៃទាំគាត់ដែរហើយមើលថៃទាំកូន!!

ខះចាំ!!

កះ ហើយអញ្ចឹង។

ខះចាំ!!

កះ  អញ្ចឹងពីមួយជំនាន់ទៅមួយជំនាន់គឺវាត្រូវតែបែបហ្នឹង!!

ខះចាំ!!

កះ តែអ្វីដែលសំខាន់គឺថាដូចថាកុំរមើលគុណស្អប់ខឹងគាត់ហាំ ដោយសារម្ដាយ!!

ខះ ញ៉ុមអត់ទេ ម្ដាយញ៉ុមញ៉ុមថៃណាស់!! ថៃទាំគាត់ណាស់ !!

កះ ចាំ!!

ខះ ថានិយាយទៅញ៉ុមអត់គាត់ពិបាកទេ!!

កៈ  ចាំអញ្ចឹងអ្នកមីងឪពុកវិញម្តង ឪពុក គាត់ឈ្មោះអីគេដែរអ្នកមីង?

ខៈ គាត់ឈ្មោះវ៉ាន់!!

កៈ  ចាំ អ៊ីចឹងឪពុកអ្នកមីងគាត់ឈ្មោះម៉ម វ៉ាន់ អ្នកមមីងណោះ?

ខៈចាំ!!

កៈ  ហ្នឹងហើយត្រកូលម៉មអញ្ចឹងនៅក្នុងសំបុត្រកំណើតគាត់កើតនៅក្នុងឆ្នាំ១៩៣៥
នៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល
ប្រទេសកម្ពុជា!!ហ្នឹងអញ្ចឹងគឺជាឪពុករបស់អ្នកមីង!! អ្នកមមីងចាំឆ្នាំខ្មែរគាត់កើតឆ្នាំអីគេឪពុក?

ខៈ គេដាក់នៅហ្នឹង អត់មានទេ?

កៈ  អត់មានទេនៅហ្នឹងហ្ន៎ឆ្នាំខ្មែរគេអត់ដាក់ផង!!!ភ្លេចឬក៏ម៉េចដែរយូរហើយ?

ខៈ ភ្លេចហើយយូរហើយ!!

កៈ  ចាំអញ្ចឹង!!

ខៈ មើលមីអូនឯងតាំងលន់ នល់ណោះមក!!

កៈ  ហ្នឹងហើយចាំ! អញ្ចឹងអ្នកមីងសំរាប់ឪពុករបស់អ្នកមីងគាត់អ្នកធ្វើការខាងអីគេដែរ
ពេលគាត់អើរពេលរៀងក្មេង
ឬក៏ពេលដូចអ្នកមីងពេលជួបគាត់អីវ៉ាន់មកធំដឹងក្តីមកគាត់ធ្វើការអីគេខ្លះអ្នកមីង?

ខៈ ធ្វើទាហានធ្វើអីអញ្ចឹងទៅ!!កម្មករកម្មអីអញ្ចឹងទៅ!!

កៈ ហ្ន៎!!

ខៈគាត់!!

កៈ  គាត់ជាទាហានលន់ នល់ មីងហេ?

ខៈ ហ្នឹងហើយ!!

ក៖ អ្នកមីងឥលូវគាត់ គាត់ស្លាប់ហើយហើយអ្នកមីងហី?

ខ៖គាត់អញ្ចេកបែកគ្នា ហើយដល់ហើយញ៉ុមរត់ទៅដល់ចុងស្ពោរហ្នំ!! រត់ទៅថា អើរអោយម៉ាក់ញ៉ុមគាត់ទៅផ្លូវផ្សេងគាត់ទៅផ្លូវផ្សេងៗ!!

ក៖ ម៉េចអញ្ចឹងវិញ?

ខ៖ ដឹងអីគាត់ចែកគ្នា!! ហើយដល់ឥឡូវមិនដឹងគាត់ស្លាប់មិនដឹងគាត់រស់ទេមកដល់ឥឡូវ មិនដែលឮដំណឹងអីផងហ្នឹង!!

ក៖ ហាំ!!ពេលហ្នឹងចូលពេលប៉ុល ពតហ្នឹងមែនទេអ្នកមីង?

ខ៖ ចូលក្នុងប៉ុល ពតហ្នឹងហាំ!!

ក៖ ហើយទោះម៉េចមិនព្រមមកជាមួយប្រពន្ធជាមួយកូនមក ស្លាប់រស់អីវ៉ាន់ទោះម៉េចក៏បានឃើញមុខគ្នាដែរអ្នកមីងណោះ?

ខ៖ ហ្នឹង !! គាត់ថាបែកផ្លូវគ្នាទៅ ហ្នឹងគាត់ថាចែកគ្នាទៅផ្លូវផ្សេងម៉ាក់ញ៉ុមទៅផ្សេង។

ក៖ និយាយថាចង់ចែកបែកគ្នាម៉ងឬក៏គ្រាន់តែជាម៉េចអ្នកមីង?ចែកផ្លូវគ្នាម៉ងហេ ?

ខ៖ហ្នឹង!!

ក៖ ចែកផ្លូវគ្នាដូចថាលែងចង់មានទំនាក់ទំនងប្តីប្រពន្ធម៉ងហេ?

ខ៖ ហ្នឹងគ្រាន់ថាទៅជាមួយអ៊ីចឹងគ្រាន់ថាគាត់ចង់ផ្លូវមួយតែឯង ញ៉ុមទៅជាមួយម៉ែអញ្ចឹងទៅណាស់!!

ក៖ ហា!អ៊ីចឹងគាត់ទៅតែម្នាក់ឯងទេអ៊ីចឹង?

ខ៖ ទៅម្នាក់ឯង។

ក៖ ហើយកូនចៅគាត់អត់?

ខ៖ អត់ទេ!!

កៈ ហើយគាត់ម៉េចបានទៅគិតអ៊ីចឹងវិញ?

ខៈដឹងអីគាត់!!

កៈ អញ្ចឹងចង់បានន័យថាអោយបន្ទុកទាំងអស់របស់កូនលើប្រពន្ធទាំងអស់!!

ខៈ ហ្នឹង !! គាត់ថាគ្រាន់តែថាអានេះដូចថា នៅក៏មិនរស់អីអញ្ចឹងណាស់!!ចែកផ្លូវគ្នាដើរទៅ!!

កៈ តែទោះម៉េចក៏យកកូនទៅតាមដែរមីងអើយ!!

ខៈ កូនអត់ទៅ កូននិយាយភាគ១០ភាគច្រើនច្រើនតែតាមម្ដាយ ឪពុកកំរតាមណាស់!!

កៈ ហើយទៅគាត់គិតឃើញអញ្ចឹងទៅញ៉ុមអត់យល់ស្របនឹងគំនិតហ្នឹងសោះ
អារឿងបែកចែកផ្លូវគ្នាអញ្ចឹងសោះ!!

ខៈ បើគាត់ទៅបែក!! បែបគាត់ស្លាប់ហើយយូរហើយ។

កៈ ចាំហ្នឹងហើយ!! អ្នកមីងគាត់ជមនុស្សយ៉ាងម៉េចដែរពេលអ្នកមីងដឹងក្ដីមកឪពុកហាំ
កាចអីអត់ឬក៏ម៉េច?

ខៈ គាត់និយាយទៅគាត់កាចណាស់ ។

កៈ ឪពុកកាចហេ?

ខៈ ចាំ!!ម៉ាក់ញ៉ូមស្លូត គាត់កាច។

កៈ ធ្លាប់វ៉ៃអីអ្នកមីងដែរហេ?

ខៈអត់ទេនៅពីទូចគាត់មិនដែលវ៉ៃទេ!!

កៈ អត់ដែរហេ?

ខៈចាំ!!

កៈ អញ្ចឹងពេលបែកគ្នាហ្នឹងអាហ្នឹងពេលប៉ុល ពតចូលមកម៉ងហើយបែកខ្ញែកគ្នាអញ្ចឹងទៅ!!!

ខ៖ ចាំគ្រាន់ថាយើងទៅជាមួយគ្នាអញ្ចឹងទៅ
យើងទៅជាមួយគ្នាទាំងអស់អញ្ចឹងទៅគាត់ទៅផ្សេងទៅ
ញ៉ុមទៅផ្សេងជាមួយម៉ាក់ញ៉ុមអញ្ចឹងទៅ ។

ក៖  អូយអារម្មណ៍ពេលហ្នឹងព្រាត់គ្នាម៉េចទៅមីងអើយ!!

ខ៖ហ្នឹង !!

ក៖  ពិបាកចិត្តណាស់ម៉ែហ្ន៎!!

ខ៖ គាត់ពីបាកចិត្តណាស់ គាត់ចេះតែទៅ ទៅផ្សេងទៅ !!

ក៖ ហ៊ឺ!!

ខ៖ ថាឯងទៅណោះទៅ ថាឯងបានរស់ញ៉ុមទៅណោះទៅញ៉ុមរស់អីអញ្ចឹង
អានេះក្នុងចិត្តគាត់គាត់គិតអញ្ចឹងទៅ!!

ក៖  ចាំ!!
តែអត់ព្រមដៅគោលដៅមួយថាទៅជួបគ្នាណាវិញអត់ទេ!!ហ៊ីយ៉ាប់ដែរហ្នឹងហាំឪ!!អញ្ចឹងអ្នកមីងចូលដល់ខាងម្ដាយរបស់អ្នកមីងដូចជាជីដូនជីតារបស់អ្នកមីងហាំ
លោកយាយគាត់ឈ្មោះអីគេដែរអ្នកមីង?

ខ៖ យាយញ៉ុមហោ?

ក៖ ចាំ!!

ខ៖ យាយញ៉ុមឈ្មោះយាយពិល!!

ក៖  អើរចាំត្រកូលរបស់យាយពិលទេ?

ខ៖ អើរដឹងតាម៉ែឪគាត់ឈ្មោះអីផង!!

ក៖ ចាំអញ្ចឹងចាំឈ្មោះតែយាយពិលមួយទេមីងហោ?

ខ៖ចាំ!!

កៈ  មីងកើតទាន់យាយពិលអត់?

ខៈញុំមហោ?

កៈ ចាំ!!

ខៈ ញុំមថាញុំមទាន់តែញុំមនៅពិនកូនមីជ្រៀចមិញហ្នឹងអញ្ចឹងណាស់!!

កៈ  អញ្ចឹងទឹមតែ៣ឆ្នាំហ្នឹងអីវ៉ាន់ហ្នឹងហោ?

ខៈ ចាំនៅទូច!!

កៈ  ម៉េចដែរមីងឃើញគាត់មក គាត់ជាមនុស្សម៉េចដែរគាត់?

ខៈ គាត់មានអីគាត់ល្អដែរ តែគ្រាន់តែថាគាត់ឈឺអាសន្នរោគហាំ!!

កៈ ហ្ហ៎ !!អញ្ចឹងគាត់ស្លាប់ទៅអ្នកមីងណោះ?

ខៈ ហ្នឹងហើយ!!

កៈ  គាំតស្លាប់មុនសង្រ្គាមឬក៏ក្រោយសង្គ្រាមមីង?

ខៈ គាត់តាំងពីលន់ នល់ ហ្ហ៎ គាត់ខូច!!

កៈ ហ្ហ៎ចាំ!!

ខៈ បើប្តីគាត់ខូចប៉ុន្មានឆ្នាំហើយ!!

កៈ  មីងពេលគាត់ស្លាប់ហ្នឹងអាយុប៉ុន្មាន?

ខៈ ញុំមហោ?

កៈ  យាយហាយាយ!!និយាយរបស់អ្នកមីងយាយពិលហាំ?

ខៈ ហ្ហ៎ដូចថាអាយុ៦០អីហើយគាត់ហ្ហ៎!!

កៈ  មីងអ់តចាំ៦០ប៉ុន្មានទេហី?

ខ៖ ហ្នឹងហើយ អត់ចាំទេ!!

ក៖  ហើយឆ្នាំណាវិញ?

ខ៖ យើងរាជលន់ នល់ហ្នឹង។

ក៖  អញ្ចឹងខ្ទង់៧០(១៩៧០)ជាងឡើងមកហ្នឹង !!

ខ៖ ហ្នឹងហើយ!!

ក៖  អញ្ចឹងខ្ទង់ចន្លោះ ៧០ ដល់៧៥ហ្នឹង(១៩៧០ ១៩៧៥)!!អញ្ចឹងនៅក្នុងចន្លោះឆ្នាំហ្នឹង!!អញ្ចឹងតាវីញមីង តាមិញឈ្មោះអីគេវិញមីង?

ខ៖ តាឈ្មោះតាឡុត !!

ក៖ ចាំ!!

ខ៖ តាឡុតយាយពិល។

ក៖ ចាំ !! ចុះមិញស្រុកកំនើតរបស់យាយពិលនៅឯណាវិញមីង?

ខ៖ ស្រុកគាត់នៅហ្នឹងដែរ!!

ក៖  នៅកោះគរហ្នឹងដែរ!!

ខ៖ចាំ!!

ក៖  នៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាលហ្នឹង!!

ខ៖ ប្ដីប្រពន្ធគាត់ស្រុកនៅហ្នឹង!!!

ក៖ ចាំ អញ្ចឹងតាមីងកើតទាន់តាដែរមែនទេ?

ខ៖ ញ៉ុមទាន់តើ!!

ក៖  តែនៅទូច?

ខ៖ ញ៉ុមធំហើយប៉ុនមីនេះហើយ!!ញ៉ុមប៉ុនមីមីហ្នឹងពេលតាញ៉ុម
ដូចកូនក្មេងឈឺអីហ្នឹងគាត់ចេះផ្លុំស្តោះ។

ក៖ ហ្វូ!!

ខ៖ ដល់ពេលកូនញ៉ុមឈឺអីហ្នឹង ញ៉ុមយកទៅអោយគាត់ផ្លុំស្តោះអី!!

ក៖ សូត្រអីវ៉ាន់អញ្ចឹងទៅ?

ខ៖ហ្នឹងហើយ!!

ក៖ មានអ្នកណាគេតវិជ្ជាហ្នឹងពីគាត់ទេមីង?

ខ៖អត់ មានអ្នកណាត!!

ក៖ ចាំ!!
មីងពេលគាត់ស្លាប់ហ្នឹងមីងអាយុប៉ុន្មានវិញ?ហ៊ីតាមពិតតាស្លាប់ក្រោយយាយមែនទេ?

ខ៖ ក្រោយហ្នឹង!!

ក៖ ក្រោយយូរហើយហ្នឹង!!ដោយសារមីងមានកូន!!

ខ៖យាយស្លាប់មុនហើយហ្នឹង!!

ក៖ មុនយូរហើយ!!

ខ៖ តាំងពីរាជលន់ នល់ ណោះ!!

ក៖ ចាំ!!តាស្លាប់ឆ្នាំណាវិញមីង?

ខ៖ មិនដឹងឆ្នាំប៉ុន្មានទេតា!!

(អ្នកជិតខាង)៖ តាស្លាប់យូរហើយ ៧៩ ៨០(១៩៧០ ១៩៨០)។

ខ៖ អើយ៧៩(១៩៧៩) ៨០គត់(១៩៨០) គាត់ស្លាប់យូរហើយគាត់វង្វេងហាំ!!

ក៖ ចាំ !! ស្លាប់ហ្នឹងបែកសង្គ្រាមមកយូរហើយ !! បែកហើយ!!

ខ៖ បែកហើយហើយ!!

ក៖  ឆ្នាំ១៩៨០គត់អីវ៉ាន់ហ្នឹងមីងហេ?

ខ៖ ហ្នឹងហើយ!!

ក៖  ហើយគាត់អាយុប៉ុន្មានវិញពេលហ្នឹង?

ខ៖ គាត់ចូលប៉ុន្មានទេនេះ !! ជ្រៀចតា តាលុចហាំ!!

ក៖  តាលុចស្លាប់!!

(អ្នកជិតខាង)៖ យូរហើយ!!៧៩(១៩៧៩)៨០គត់(១៩៨០)។

ក៖  ប៉ុន្តែអាយុគាត់ហាមីងហាំ?

(អ្នកជិតខាង)៖ អាយុគាត់កាលស្លាប់មិនដឹងប៉ុន្មានភ្លេចបាត់ហើយ!!៧០ហើយទេ!!

ខ៖ ចូល៧០ហើយ!!

ក៖  ហ្ហ៎ ចូល៧០ហើយ!!អញ្ចឹងចាស់ដែរហើយហេ?

ខ៖ ចាស់ហើយពេលគាត់ស្លាប់ ចូល៧០ហើយគាត់ហ្ហ៎!!

ក៖ ចាំហ្នឹងហើយ!! អ៊ីចឹងអ្នកមីងសំរាប់ចូលដល់ !តែគាត់ខាងអ្នកភូមិកោះគរហ្នឹងដែរ?

ខ៖ ចាំ!!

ក៖  ចាំហ្នឹងហើយ
អញ្ចឹងអ្នកមីងសំរាប់ចូលដល់ជីវិតជីដូនជីតាខាងឪពុកវិញម្ដងម៉េចខាងម្ដាយអ្នកមីងណោះ?

ខ៖ចាំ!!

ក៖ អញ្ចឹងខាងឪពុកវិញតាឈ្មោះអីគេដែរអ្នកមីង?

ខ៖ តា ឪពុកតាឈ្មោះតាម៉ម។

ក៖ ចាំ!!ចាំត្រកូលគាត់ទេអ្នកមីង?

ខ៖ អត់ចាំទេ។

ក៖ ចាំ ង្អកមីងកើតទាន់តាម៉នទេ?

ខ៖ ញ៉ុមអត់ទាន់ទេ !! ញ៉ុមឮតែបងប្អូនជីដូនមួយញ៉ុមនិយាយ។

ក៖ គាត់និយាយអីគេវិញមីង?

ខ៖ គាត់និយាយថាតាឈ្មោះតាម៉មហើយយាយអី តែយាយញ៉ុមភ្លេចហើយ!!

ក៖ ចាំ តែយាយអត់ចាំទេមីងហេ?

ខ៖ អត់!!

ក៖ ចាំមានដែលឪពុកអ្នកមីងមានដែលជំនាលរឿងប្រាប់ពីជីដូនជីតាអីអត់?

ខ៖ អត់!!

ក៖ ដូចអត់ដែលបានប្រាប់ពីជីដូនជីតាហ្នឹងម៉ងហេ?

ខ៖ គាត់ប្រាប់អញ្ចឹងតែគ្រាន់តែយើងនៅចាំហាំ គាត់ប្រាប់តើ!!

ក៖ ចាំ!!
អ្នកមីងមានអីគេដែលចងចាំពីឪពុកម្ដាយឬក៏ជីដូនជីតាអីចង់រៀបរាប់ប្រាប់ពីជីវិតរបស់អ្នកមីងទៀតទេមីង?ដូច ដូច ជាចាំបន្ថែមទៀតអីអញ្ចឹងទៅណាស់!!

ខ៖ ចាំ គាត់ពិបាកវេទនាណាស់ ម៉ែឪញ៉ុមពិបាកណាស់!!

ក៖ មនុស្សជំនាន់មុនអីអឺចឹងទៅមីងណោះ?

ខ៖ចាំ!!

ក៖ តាដូចជាជីដូនជីតា តាគាត់រកស៊ីអីគេដែរអ្នកមីងពេលជំនាន់ហ្នឹង?

ខ៖ គាត់ធ្វើស្រែចំការ។

កៈ  តាខាងឪពុកគាត់អ្នកភូមិកោះគរ អ្នកស្រុកកោះគរហ្នឹងដែរមីងហេ?

ខៈ ចាំ នៅភូមិកោះគរហ្នឹងទាំងអស់។

កៈ  អ្នកមីងសំរាប់បងប្អូនអ្នកមីង
ដូចជាដូនតាអីវ៉ន់មកមានឮដែលធ្លាប់ថាដែលឮគេធ្លាប់ទៅរស់នៅប្រទេសក្រៅទេអ្នកមីង?

ខៈ អត់!!

កៈ  នៅតែស្រុកខ្មែរយើងហ្នឹងមួយទេហេ?

ខៈចាំ!!

កៈ  ហ្នឹងហើយ!!ហើយចុះដែលមានធ្លាប់បងប្អូនណាធ្វើការនៅប្រទេសថៃអីអត់ទេអ្នកមីង?

ខៈ អត់!!

កៈ  នៅតែប្រទេសខ្មែរយើងហ្នឹងមួយទេ?

ខៈ ប្រទេសខ្មែរ។

កៈ
អ្នកមីងអ្នកមីងចេះសរសេរនិងនិយាយភាសាខ្មែរអីបានទាំងអស់តើមីងហេ?ហ៊ីនិយាយដឹងតែបានហើយច្រឡំ! តែចេះអានចេះសរសេរអីអត់?

ខៈ អត់!!

កៈ អត់ចេះម៉ងហេ?

ខៈ ចាំ!!

កៈ ចាំ ហ្នឹងហើយ ព្រោះអីអញ្ចេកញ៉ុមឈប់រៀនត្រឹមថ្នាក់ទី២ មិនទាន់សួរចេះអីហាំ!!

កៈ ហ៊ឺ!!

ខៈ ហើយណាមួយប៉ាញ៉ុមហ្នឹងហាំ!!ញ៉ុមទៅមើលថៃគាត់ដែរ។

ក៖ ចាំ!!ក៏អត់នេះទៅ!!

ខ៖ ចាំអ៊ីចឹងអត់បានរៀនបានអីទេ!!

ក៖  ហ៊ឺ!!ចាំ ហ្នឹងហើយ!!!ចាំ!!

ខ៖ មានចេះអក្សរអីញ៉ុម!!

ក៖
ចាំអញ្ចឹងអរគុណច្រើនអ្នកមីងអំពីប្រវត្តិរបស់អ្នកមីងអំពីប្រវត្តិដូនតាហើយអ្វីទាំងអស់កូនចៅរបស់អ្នកមីងគាត់នឹងបានស្ដាប់ឮអ្នកមីងបានដំណាលពីជីវិតរបស់អ្នកមីងក៏ដូចជាក្រុមគ្រួសារអ្នកមីងផងដែរហើយអោយអ្វីៗទាំងអស់ពួកគាត់នឹងដឹងឮអំពីជីវិតរបស់ដូនតារបស់គាត់ហាំអ្នកមីង!!

ខ៖ចាំ!!